**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ ...០២៣ ស.ជ.លទ..

ថ្ងៃព្រហ.០១.រោច.ខែ.មាឃ..ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី.០១..ខែ.កុម្ភៈ...ឆ្នាំ ២០១៨

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីសាងសង់/ជួសជុល និងផ្គត់ផ្គង់នូវទំនិញ ដូចខាងក្រោម៖

១-កញ្ចប់"ក"៖ ការសាងសង់ក្លោងទ្វារ និងរបងប្រវែង៩២ម, សាងសង់អគារស្នាក់នៅរបស់គ្រូបង្រៀនចំនួន១ខ្នងមាន០៤បន្ទប់ ទំហំ៥.៥មx២០ម និងជួសជុល-លាបថ្នាំអគារសិក្សាចាស់ ចំនួន១ខ្នងមាន០៣បន្ទប់ ព្រមទាំងបន្ទប់ទឹក១ខ្នងមាន២បន្ទប់ និង១ខ្នងទៀតមាន៣បន្ទប់ស្ថិត ក្នុងភូមិចំការ៣ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប

២-កញ្ចប់"ខ"៖ ការផ្គត់ផ្គង់រ៉ូប៊ីណេស្កាន់ បំពង់អ៊ីណុក និងសម្ភារតភ្ជាប់អ៊ីណុក

៣-កញ្ចប់"គ"៖ ការផ្គត់ផ្គង់សម្ភារតភ្ជាប់ប៉េអឺ

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្ដីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ ត្រឹមវេលាម៉ោង ១៦:០០រសៀល ក្នុងមួយច្បាប់តម្លៃ ២០០,០០០រៀល សម្រាប់កញ្ចប់ "ក" និង ៤០០,០០០រៀល សម្រាប់កញ្ចប់ "ខ,គ"។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨ កញ្ចប់"ក"វេលាម៉ោង១៤:៣០នាទី, កញ្ចប់"ខ"វេលាម៉ោង១៤:៥០នាទី និងកញ្ចប់"គ"វេលាម៉ោង១៥:១០នាទី នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធានទី១**

**បណ្ឌិត ជា វិសុទ្ធ**

ចម្លងជូន៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

"ដើម្បីជ្រាបជាព័ត៌មាន"

-ឯកសារ-កាលប្បវត្តិ